ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ: ៧៩៩២ ន.ទ.ក.

# សេចក្តីជូនដំណឹង

# ស្តីពី

# ការកើនឡើងនៃការឆបោកតាមរយៈថ្នាលតេឡេក្រាម (Telegram)

និយ័តករទូរគមនាគមន៍កម្ពុជា(ន.ទ.ក.) សង្កេតឃើញពីការកើនឡើងនៃការផ្ញើសារឆបោកតាមរយៈថ្នាលតេឡេក្រាម(Telegram) ដោយជនឆបោកទាំងនោះបានប្រើប្រាស់វិធីសាស្ត្រក្នុងទម្រង់និងរូបភាពផ្សេងៗ ដូចជា÷

- ប្រើប្រាស់ឈ្មោះនិងរូបភាពរបស់បុគ្គលសាធារណៈល្បីៗ ថ្នាក់ដឹកនាំក្រសួង/ស្ថាប័ន ឬថ្នាក់ដឹកនាំក្រុមហ៊ុន បង្កើតកម្មវិធីវិនិយោគក្លែងក្លាយ ដើម្បីអូសទាញសាធារណជនឱ្យធ្វើការវិនិយោគដោយសន្យាថានឹងទទួលបានផលចំណេញខ្ពស់ក្នុងរយៈពេលដ៏ខ្លី។
- ផ្ញើសារជូនដំណឹងអំពីការឈ្នះរង្វាន់ និងតម្រូវឱ្យអ្នកទទួលបានសារទាំងនោះផ្តល់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានហិរញ្ញវត្ថុ ដើម្បីអាចទទួលបានរង្វាន់ទាំងនោះ។
- ក្លែងបន្លំជាក្រុមហ៊ុនតេឡេក្រាម ផ្ញើសារបំភិតបំភ័យដោយបញ្ជាក់ថាគណនីកំពុងត្រូវបានលួច ឬមានភាពមិនប្រក្រតី និងតម្រូវឱ្យអ្នកទទួលបានសារនោះផ្តល់នូវលេខសម្ងាត់ ឬព័ត៌មានចាំបាច់មួយចំនួន ដើម្បីផ្ទៀងផ្ទាត់គណនី។

ដើម្បីការពារសុវត្ថិភាពពីការឆបោកទាំងនេះ សូមសាធារណជន ធ្វើការពិនិត្យនិងផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបាន កុំចែករំលែកលេខសម្ងាត់ ឬព័ត៌មានផ្ទាល់ខ្លួនទៅកាន់អ្នកដទៃ កុំចុចលើតំណភ្ជាប់ដែលមានការសង្ស័យ និងអនុវត្តវិធីសាស្ត្រពាក់ព័ន្ធនឹងមុខងាររបស់តេឡេក្រាម ដូចខាងក្រោម÷

- ដាក់ដំណើរការមុខងារផ្ទៀងផ្ទាត់ពីរជំហាន (Two-Step Verification - 2FA) ដែលអ្នកប្រើប្រាស់ត្រូវមានការផ្ទៀងផ្ទាត់បន្ថែមមួយទៀត ពីលើការប្រើប្រាស់លេខទូរស័ព្ទនិងកូដដែលទទួលបានដើម្បីចូលទៅក្នុងគណនីតេឡេក្រាម។
- ប្រើប្រាស់ពាក្យសម្ងាត់រឹងមាំ ដែលមានយ៉ាងហោចណាស់ ៨ ខ្ទង់, ពិបាកទាយដឹងដោយរួមបញ្ចូលលេខ និមិត្តសញ្ញា អក្សរធំនិងអក្សរតូច, ជៀសវាងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន, កុំប្រើប្រាស់ឡើងវិញនូវពាក្យសម្ងាត់ដែលធ្លាប់ប្រើ និងត្រូវផ្លាស់ប្តូរពាក្យសម្ងាត់ឱ្យបានទៀងទាត់។

- ពិនិត្យមើល Active Sessions ដែលអ្នកប្រើប្រាស់អាចមើលរាល់ Sessions ទាំងអស់ដែលកំពុងប្រើប្រាស់គណនីតេឡេក្រាមរបស់ខ្លួន និងពិនិត្យមើលថាតើមាន Active Sessions ណាមួយដែលគួរឱ្យសង្ស័យដែរឬទេ។
- ប្រើមុខងារ Passcode Lock ដែលអ្នកប្រើប្រាស់អាចចាក់សោកម្មវិធីដោយប្រើលេខកូដសម្ងាត់ដើម្បីការពារនៅពេលដែលចូលប្រើប្រាស់តេឡេក្រាមនៅលើឧបករណ៍។

ន.ទ.ក. សូមអំពាវនាវដល់សាធារណជន ទាក់ទងមក ន.ទ.ក. តាមរយៈទូរស័ព្ទលេខ ៦៧៨៩ នៅរៀងរាល់ម៉ោងធ្វើការ ឬការផ្ញើសារមកកាន់អ៊ីមែល info@trc.gov.kh ឬមកកាន់ហ្វេសប៊ុក “**និយ័តករទូរគមនាគមន៍កម្ពុជា - Telecommunication Regulator of Cambodia**” ករណីមានតម្រូវការសាកសួរព័ត៌មានបន្ថែម ឬជួបប្រទះបញ្ហាដូចបានជម្រាបជូនខាងលើ។

ថ្ងៃចន្ទ ៨ រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥